# មេរៀនទី ៩៥៖ នាងរស់រៀបការជាមួយបូអូស

## នាងរស់ ២-៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/ae7z3T0Swb0

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/aTnWt6rFDU4

**គោលបំណង៖ ព្រះគឺជាអ្នកគ្រប់គ្រង។**

**ខគម្ពីរចងចាំ៖ ចោទិយកថា ៣១៖៨** *"គឺព្រះយេហូវ៉ាដែលនឹងយាងនាំមុខឯងទៅ ព្រមទាំងគង់ជាមួយនឹងឯង ទ្រង់មិនដែលខាននឹងប្រោសឯងឡើយ ក៏មិនដែលលះចោលឯងដែរ ដូច្នេះកុំឲ្យខ្លាច ឬស្រយុតចិត្តឲ្យសោះ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំសប្បាយរីករាយ https://youtu.be/2LWPsq-KZvo
២. បើអ្នកសប្បាយក្នុងព្រះយេស៊ូវ https://youtu.be/SsldqdQB-9U
៣. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ធ្វើឲ្យសើច»



១. ចែកកុមារជាពីរក្រុមគឺក្រុម ក និងខ
២. ក្រុម ក នឹងជ្រើសរើសកុមារណាម្នាក់មកធ្វើជាអ្នកធ្វើកាយវិការ តែមិនត្រូវបញ្ចេញសម្លេងនោះទេ។ គ្រូត្រូវកំណត់នាទីក្នុងការធ្វើកាយវិការ ប្រសិនបើសមាជិកក្រុម ខ ណាម្នាក់សើច នោះក្រុម ក នឹងឈ្នះល្បែងនេះ។
៣. ប្រសិនបើក្រុម ខ មិនសើចទេ នោះក្រុម ក និងចាញ់ល្បែងនេះ។
៤. បន្តលេងល្បែងនេះ ដោយប្តូរអ្នកធ្វើកាយវិការ។
៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ក្រុមណាដែលមិនអាចគ្រប់គ្រងការសើចរបស់ខ្លួនឯងបាននឹងចាញ់ល្បែងនេះ។ មានពេលខ្លះយើងបាត់បង់ការគ្រប់គ្រងលើអ្វីៗគ្រប់យ៉ាងនៅក្នុងជីវិតរបស់យើង ប៉ុន្តែថ្ងៃនេះយើងនឹងរៀនពីព្រះដែលទ្រង់តែងតែស្ថិតក្នុងការគ្រប់គ្រងជានិច្ច។

## ៤. ការណែនាំមេរៀន

មានពេលខ្លះរឿងរ៉ាវដែលកើតឡើងនៅក្នុងជីវិតរបស់យើងហាក់ដូចជាមិនអាចគ្រប់គ្រងបាន។ ហើយមានពេលខ្លះ នៅពេលដែលមានរឿងមិនល្អកើតឡើង ពួកយើងមានការភ័ន្តច្រឡំ ហើយមិនដឹងថា ខ្លួនឯងត្រូវធ្វើអ្វីនោះទេ។ ថ្ងៃនេះយើងនឹងរៀនពីរឿងនៅក្នុងព្រះគម្ពីរ សូម្បីតែពេលដែលយើងបាត់បង់ និងច្របូកច្របល់ក៏ដោយ ក៏ព្រះទ្រង់គ្រប់គ្រង ហើយមិនដែលខកខានក្នុងការមើលថែរក្សាពួកយើងឡើយ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះគម្ពីរនេះបានប្រាប់ពីរឿងរ៉ាវមួយដែលបង្ហាញថា ព្រះជាម្ចាស់គឺជាអ្នកគ្រប់គ្រង។ គឺនិយាយអំពីស្ត្រីម្នាក់

ឈ្មោះ ន៉ាអូមី ប្រពន្ធកូនប្រុសគាត់មានឈ្មោះថា នាងរស់ ហើយនិងបុរសចិត្តល្អម្នាក់ឈ្មោះ បូអូស។ ន៉ាអូមី និងកូនប្រសារ នាងរស់ បានត្រឡប់ទៅបេថ្លេហិម(អ៊ីស្រាអែល)វិញ។ ណាអូមីចង់ឲ្យ នាងរស់ស្នាក់នៅស្រុក ម៉ូអាប់ ជាមួយក្រុមគ្រួសាររបស់នាង ប៉ុន្តែ នាងរស់បានទទូចសុំនៅជាមួយ ន៉ាអូមី ព្រោះនាងស្រឡាញ់ ន៉ាអូមី ហើយចង់មើលថៃគាត់។ ណាអូមី និងនាងរស់ គឺជាស្ត្រីមេម៉ាយ ដែលប្តីរបស់ពួកគេបានស្លាប់។

ពេលពួកគេត្រឡប់ទៅបេថ្លេហិមវិញ គ្មានការងារណាសម្រាប់ស្ត្រីមេម៉ាយធ្វើទេ។ នៅសម័យនោះ អ្នកក្រីក្រ អាចទៅចម្ការរបស់កសិករ ហើយរើសស្រូវដែលធ្លាក់លើដីបន្ទាប់ពីច្រូតកាត់រួច។ ដូច្នេះ នាងរស់ បានទៅស្រែមួយ ហើយរើសស្រូវនៅវាលសម្រាប់ ន៉ាអូមី និងខ្លួននាង។ នាងរស់មិនដឹងទេថាម្ចាស់ដីនោះ គឺជាបុរសចិត្តល្អម្នាក់ឈ្មោះ បូអូស ដែលជាសាច់ញាតិជិតស្និតប្តីរបស់ន៉ាអូមី។

បូអូសបានឃើញថា នាងរស់មានសណ្តានចិត្តល្អ ហើយឧស្សាហ៍ព្យាយាមទៀត។ គាត់បានឃើញថានាងមើលថៃ ន៉ាអូមីយ៉ាងល្អ។ បូអូសមានចិត្តសប្បុរសចំពោះនាងរស់ ហើយបានធ្វើឱ្យប្រាកដថា នាងរស់មានអាហារគ្រប់គ្រាន់សម្រាប់ខ្លួននាង និងន៉ាអូមី។ ពេលន៉ាអូមីឃើញស្បៀងអាហារ នាងភ្ញាក់ផ្អើលណាស់។ ហើយន៉ាអូមី បានប្រាប់នាងរស់ថា បូអូស គឺជាសាច់ញាតិជិតស្និទ្ធរបស់នាង។

ន៉ាអូមីអាចមើលឃើញថា បូអូសនឹងក្លាយជាប្តីដ៏ល្អរបស់នាងរស់។ ន៉ាអូមីបានចាត់ទុកនាងរស់ជាកូនស្រីរបស់គាត់។ ច្បាប់របស់ព្រះជាម្ចាស់បានចែងថា នៅពេលដែលស្ត្រីវ័យក្មេងក្លាយជាស្ត្រីមេម៉ាយ បុរសដែលជាសាច់ញាតិជិតបំផុតរបស់ប្តីនាងដែលបានស្លាប់នោះគួរតែរៀបការជាមួយស្ត្រីមេម៉ាយនោះ ហើយគួរតែទិញដីដែលជាកម្មសិទ្ធិរបស់ប្តីនាងមកវិញ។ តាមរយៈការនេះ ព្រះបានប្រទានដីនោះ ឲ្យដល់ក្រុមគ្រួសារដដែលជាអ្នកកាន់កាប់។

ពេលបូអូសបានដឹងថា នាងរស់សុខចិត្តរៀបការជាមួយគាត់ គាត់ត្រូវរកមើលសាច់ញាតិដែលជិតស្និតនឹងគ្រួសាររបស់ន៉ាអូមី ព្រោះអ្នកដែលជាសាច់ញាតិជិតស្និតអាចមានសិទ្ធិស្របច្បាប់ច្រើនជាង ក្នុងការរៀបការជាមួយនាងរស់។ បូអូសបានផ្តល់ឱកាសក្នុងការរៀបការជាមួយនាងរស់ ឲ្យទៅសាច់ញាតិផ្សេងទៀតជាមុនសិន។ ប៉ុន្តែសាច់ញាតិម្នាក់នោះ ត្រូវទិញទ្រព្យសម្បត្តិរបស់ន៉ាអូមីមកវិញ ដើម្បីរៀបការជាមួយនាងរស់។ សាច់ញាតិនោះ បានលះបង់សិទ្ធិនោះទៅឲ្យបូអូស។ បូអូសនិងនាងរស់បានរៀបការជាមួយគ្នា ហើយមានកូនប្រុសម្នាក់ឈ្មោះថា អូបិឌ ដែលជាជីតារបស់ស្តេចដាវីឌ!

នៅពេលដែល ន៉ាអូមី និងនាងរស់បាត់បង់ប្តីពួកគាត់ក៏ក្លាយទៅជាស្ត្រីមេម៉ាយ ហើយជីវិតរបស់ពួកគាត់គឺពិតជាពិបាកខ្លាំងណាស់។ មិនថាបន្ទាប់ពីគាត់ត្រឡប់ទៅ បេថ្លេហិមវិញហើយក៏ដោយក៏ការរស់នៅរបស់ពួកគាត់មិនងាយស្រួលនោះទេ។ ប៉ុន្តែព្រះជាអ្នកគ្រប់គ្រងស្ថានការនោះ។ វាមិនមែនជាការងាយស្រួលនោះទេ មិនថាពេលខ្លះយើងពិបាកនឹងគិតឃើញថា ការអាក្រក់ទាំងអស់នោះ កើតឡើងបានយ៉ាងដូចម្តេច តែសូមឲ្យយើងចងចាំថា ព្រះគឺអាចគ្រប់គ្រងស្ថានការទាំងអស់នោះបាន។ នៅពេលដែលយើងមានជំនឿដោយទុកចិត្តលើព្រះ ហើយដើរតាមទ្រង់ មិនថាពេលវេលាលំបាកយ៉ាងណានោះទេ យើងនឹងទទួលបាននូវបទពិសោធន៍ពីព្រះគុណរបស់ព្រះ។

ព្រះទ្រង់ស្រលាញ់អ្នកហើយដឹងគ្រប់យ៉ាងពីអ្នក។ ព្រះអង្គដឹងពីអ្វីដែលធ្វើឲ្យអ្នកសប្បាយចិត្ត និងអ្វីដែលធ្វើឲ្យអ្នកមានការភ័យខ្លាច។ ទ្រង់មានផែនការដ៏អស្ចារ្យសម្រាប់អ្នក និងជីវិតរស់នៅរបស់អ្នក។ ហើយទ្រង់បានសន្យាថា ផែនការរបស់ទ្រង់តែងតែល្អជានិច្ច។ ទ្រង់បានរក្សាយើងទាំងអស់ជាប់នៅក្នុងព្រះហស្ត

របស់ទ្រង់។ ហើយយើងមិនចាំបាច់បារម្ភថា នឹងមានរឿងអ្វីកើតឡើងចំពោះយើងនោះទេ ពីព្រោះព្រះទ្រង់ជាអ្នកគ្រប់គ្រងរាល់ស្ថានការទាំងអស់។

## ៦. សំនួរពិភាក្សា

១. តើនាងរស់បានធ្វើអ្វីដើម្បីរកម្ហូបអាហារសម្រាប់នាងនិងន៉ាអូមី?
*(នាងបានទៅរើសគួរស្រូវដែលជ្រុះ នៅពេលច្រូតកាត់ ដែលជាដីស្រែរបស់បុរសម្នាក់)*
២. តើនរណាជាម្ចាស់ដីស្រែនោះ ហើយតើគាត់ត្រូវជាអ្វីនឹងន៉ាអូមី?
*(បូអូសជាម្ចាស់ដីស្រែនោះ ហើយ គាត់ ត្រូវជាសាច់ញាតិជិតស្និតរបស់ន៉ាអូមី)*
៣. តើអ្នកគិតថានាងរស់អាចរើសស្រូវនៅក្នុងដីស្រែរបស់បូអូសបានដោយរបៀបណា ព្រោះគាត់មិនទាំងស្គាល់បូអូសផងនោះ? *(នេះគឺជាផែនការរបស់ព្រះ ហើយព្រះទ្រង់ជាអ្នកគ្រប់គ្រង)*
៤. តើអ្វីដែលធ្វើឲ្យអ្នកជឿជាក់ថាព្រះជាអ្នកគ្រប់គ្រងលើជីវិតរបស់អ្នក? *(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត «អាឡូ»




១. ឲ្យកុមារប៉ាវរកអ្នកចាញ់ចុងក្រោយម្នាក់ ហើយឲ្យគេធ្វើជា អ្នកចាំទី
២. កុមារត្រូវរត់ក្នុងបរិវេណថ្នាក់រៀន
៣. អ្នកអាចនិយាយពាក្យថា "អាឡូ" នៅពេលដែលអ្នកមិនចង់ឲ្យអ្នកចាំទីចាប់បាន។ អ្នកអាចបន្តរត់លេងបាន នៅពេលដែលមាននរណាម្នាក់មកប៉ះអ្នក ដែលមិនមែនជាអ្នកចាំទី។
៤. បើអ្នកចាំទី ប៉ះអ្នកបានមុនពេលដែលអ្នកនិយាយពាក្យថា "អាឡូ" នោះអ្នកនឹងក្លាយជាអ្នកចាំទីវិញម្តង។
៥. បន្ទាប់ពីលែងល្បែងនេះចប់ សូមពន្យល់កុមារថា យើងអាចស្រែកថា "អាឡូ" ដើម្បីកុំឲ្យអ្នកចាំទី ចាប់យើងបាន។ ហើយនៅក្នុងវិធីដូចគ្នានេះ យើងក៏អាចស្រែកហៅ "ព្រះ" ដើម្បីជួយយើងឲ្យរួចផុតពីបញ្ហានៅក្នុងលោកីយ៍នេះបានដែរ។ សូមចាំថា ព្រះទ្រង់តែងតែគ្រប់គ្រង និងថែរក្សាយើងជានិច្ច។

## ៨. ខគម្ពីរចងចាំ

**ចោទិយកថា ៣១៖៨** *"គឺព្រះយេហូវ៉ាដែលនឹងយាងនាំមុខឯងទៅ ព្រមទាំងគង់ជា មួយនឹងឯង ទ្រង់មិនដែលខាននឹងប្រោសឯងឡើយ ក៏មិនដែលលះចោលឯងដែរ ដូច្នេះកុំឲ្យខ្លាចឬស្រយុតចិត្តឲ្យសោះ។"*

## ៩. ហាត្ថកម្ម «ព្រះគឺជាអ្នកគ្រប់គ្រង»







សម្ភារៈដែលត្រូវការ៖ កន្ត្រៃ កូល័រទៀន និងបោះពុម្ពក្រដាស (នៅទំព័រខាងក្រោម)
១. កាត់ក្រដាស រូបបាតដៃ បេះដូង និងរូបផែនទីចេញមក។
២. សូមផាត់ពណ៌នៅលើរូប បាតដៃ បេះដូង និងផែនទី។
៣. សរសេរពាក្យថា "ព្រះគឺជាអ្នកគ្រប់គ្រង" នៅលើ រូបបេះដូង ហើយយកវាទៅបិទនៅលើរូបផែនទី។
៤. សូមបិតរូបបាតដៃនៅលើផ្នែកសងខាងរបស់ផែនទី។

៥. សូមឲ្យកុមារទាំងអស់លើករូបហត្ថកម្មរបស់ពួកគេឡើង ហើយនិយាយថា “ខ្ញុំមិនត្រូវខ្លាចអ្វីទាំងអស់ ព្រោះព្រះជាអ្នកគ្រប់គ្រងខ្ញុំ!”

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
នៅក្នុងជីវិតរស់នៅរបស់យើងមានរឿងជាច្រើន ដែលយើងមើលទៅវាហាក់បីដូចជាការចៃដន្យ តែតាមពិតទៅព្រះទេ ជាអ្នកធ្វើការនោះ។ សូមមើលទៅព្រះគម្ពីរ **នាងរស់ ៤៖១៣-១៧** មានមួយនៅក្នុងនោះ ដែលយើងមើលទៅវាហាក់បីដូចជាការចៃដន្យដែលនាងរស់បានរើសស្រូវក្នុងស្រែរបស់ បូអូស ដែលជាសាច់ញាតិជិតស្និតរបស់ម្តាយក្មេកគាត់។ ប៉ុន្តែវាគឺជាការចៃដន្យឬ? ទេអត់ទេ! វាគឺជាផែនការរបស់ព្រះ! តើអ្វីដែលជាផែនការចុងក្រោយរបស់ព្រះដែលមានសម្រាប់នាងរស់ នៅពេលដែលនាង សម្រេចចិត្តរស់នៅជាមួយន៉ាអូមី? តើអ្វីដែលជាការសម្រេចចិត្តដ៏ត្រឹមត្រូវរបស់អ្នក ដែលធ្វើឲ្យអ្នកទទួលបាននូវលទ្ធផលល្អនៅក្នុងជីវិតរបស់អ្នកដែលឬទេ? តើបទពិសោធន៍នោះបានជួយឲ្យអ្នកមាន សេចក្តីសង្ឃឹមបែបណាចំពោះព្រះ? សូមចាំថាព្រះតែងតែគង់នៅជាមួយអ្នក ហើយទ្រង់តែងតែទតមើលអ្នក។ តាមរយៈសាច់រឿងនៅក្នុងមេរៀនថ្ងៃនេះ សូមជួយសិស្សឲ្យបានយល់ថា ព្រះគឺជាអ្នកគ្រប់គ្រង។

# ព្រះគឺជាអ្នកគ្រប់គ្រង

